កំណត់សំគាល់: សាលក្រមនេះគឺជារឿងក្តីជាក់ស្តែង ហើយមិនមែនជាសាលក្រមគម្រូទេ

0022

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

សាលាដំបូងរាជធានីភ្នំពេញ

សាលក្រមរដ្ឋប្បវេណី

លេខ ១០១៥ "ម"

ចុះថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩

សំណុំរឿងរដ្ឋប្បវេណី

លេខ ២៥៧៨

ចុះថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៨

**<u>គោរពនាមប្រជារាស្ត្រខ្មែរ</u>**

**<u>សាលាដំបូងរាជធានីភ្នំពេញ</u>**

**បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ នាថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០១៩។**

**សាលក្រមប្រកាសជាសាធារណៈ នាថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩។**

-លោក **ហុង សុគុណា ចន្ទ្យនា** ចៅក្រមនៃសាលាដំបូងរាជធានីភ្នំពេញ។

-លោក **លី សូលីដា** ក្រឡាបញ្ជីនៃសាលាដំបូងរាជធានីភ្នំពេញ។

**រវាង** ដើមចោទ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** ដ អាសយដ្ឋាននៅ រាជធានីភ្នំពេញ ដែលមានតំណាងដោយលោក តដ ។

**និង** សហចុងចម្លើយឈ្មោះ ច១ អាយុ ៥០ឆ្នាំ និងប្រពន្ធឈ្មោះ ច២ អាយុ ៤៦ឆ្នាំ មានទីលំនៅ រាជធានីភ្នំពេញ។

**<u>ខ្លឹមសារនៃសាលក្រមដែលទាមទារដោយដើមចោទៈ</u>** ប្តឹងសុំឱ្យតុលាការចេញសាលក្រមសម្រេចបង្គាប់ឱ្យសហចុងចម្លើយរួមគ្នាសង នូវៈ

១-ប្រាក់ដើមចំនួន២៣,៨០០(ពីរម៉ឺនបីពាន់ប្រាំបីរយ)ដុល្លារអាមេរិក។

២-ការប្រាក់ចំនួន១.៣០(មួយក្បៀសសាមសិប)ភាគរយក្នុងមួយខែ នៃប្រាក់ដើមចំនួន២៣,៨០០(ពីរម៉ឺនបីពាន់ប្រាំបីរយ) ដុល្លារអាមេរិក គិតចាប់ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ រហូតដល់សងអស់។

៣-ប្រាក់ពិន័យចំនួន២(ពីរ)ដុល្លារអាមេរិក ក្នុងមួយថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ រហូតដល់សងអស់។

៤-សំណងការខូចខាតពេលវេលា និងជម្ងឺចិត្តចំនួន៤,០០០,០០០(បួនលាន)រៀល។

៥-សុំឱ្យតុលាការប្រកាសសាលក្រមនេះមានអនុភាពអនុវត្តជាបណ្តោះអាសន្នលើប្រាក់ដើម។

៦-ប្រាក់ប្រដាប់ក្តី ជាបន្ទុករបស់សហចុងចម្លើយ។

**<u>អង្គហេតុ និងចំណុចវិវាទ</u>**

**១-<u>អង្គហេតុ:</u>**

-ក្នុងរឿងក្តីនេះ គឺសហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បានខ្ចីប្រាក់ពីគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ចំនួន២៣,៨០០ដុល្លារអាមេរិក ដែលមានកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧។ ក្រោយពេលខ្ចីប្រាក់រួច សហចុងចម្លើយបានបង់ប្រាក់តាមការកំណត់ក្នុងកិច្ចព្រមព្រៀងជាបន្តបន្ទាប់បានចំនួន០៤ខែ។ ក្រោយមក សហចុងចម្លើយមិនបានបង់ប្រាក់មកឱ្យដើមចោទរហូតមកដល់បច្ចុប្បន្ន ដោយនៅជំពាក់ប្រាក់ដើមចំនួន២៣,៨០០ដុល្លារអាមេរិក។ ម្យ៉ាងទៀត នៅដំណាក់កាលនីតិវិធីត្រៀមសម្រាប់ការទាញហេតុផល សហចុងចម្លើយក៏បានទទួលស្គាល់ការទាមទាររបស់ដើមចោទដែរ។

២-<u>សេចក្តីថ្លែងការណ៍របស់គូភាគី</u>

**ក**-តំណាងដើមចោទ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** ដ លោក តដ បានថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថាៈ កាលពីថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ ↪

សហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បានខ្ចីប្រាក់ពីធនាគារគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ចំនួន២៣,៨០០ដុល្លារអាមេរិក ដោយមានកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ និងអត្រាការប្រាក់ចំនួន១.៣០ភាគរយ ក្នុងមួយខែ គឺស្មើនឹងទឹកប្រាក់ចំនួន៣០៩ដុល្លារអាមេរិក។ ដែលមានរយៈពេលកំណត់៦០ខែ។ ក្រោយពីខ្ចីប្រាក់ពីធនាគារមក សហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ បានបង់ការប្រាក់រយៈពេលពីរខែសរុបចំនួន៥០០ ដុល្លារអាមេរិក ប៉ុណ្ណោះ។ ក្រោយមកសហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ មិនបានបង់ប្រាក់ដើម និងការប្រាក់មកធនាគាររបស់ខ្លួនរហូតដល់បច្ចុប្បន្ននេះ។ ដូច្នេះ ទឹកប្រាក់ដែលនៅជំពាក់ធនាគារមានចំនួន២៣,៨០០ដុល្លារអាមេរិក។

<u>សំណូមពរ:</u> សុំឲ្យតុលាការចេញសាលក្រមសម្រេចដោយបង្គាប់ឲ្យសហចុងចម្លើយរួមគ្នាសង នូវ:

១-ប្រាក់ដើមចំនួន២៣,៨០០(ពីរម៉ឺនបីពាន់ប្រាំបីរយ)ដុល្លារអាមេរិក។

២-ការប្រាក់ចំនួន១.៣០(មួយក្បៀសសាមសិប)ភាគរយក្នុងមួយខែ នៃប្រាក់ដើមចំនួន២៣,៨០០(ពីរម៉ឺនបីពាន់ប្រាំបីរយ) ដុល្លារអាមេរិក គិតចាប់ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ រហូតដល់សងអស់។

៣-ប្រាក់ពិន័យចំនួន២(ពីរ)ដុល្លារអាមេរិក ក្នុងមួយថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ រហូតដល់សងអស់។

៤-សំណងការខូចខាតពេលវេលា និងជម្ងឺចិត្តចំនួន ៤,០០០,០០០(បួនលាន)រៀល។

៥-សុំឲ្យតុលាការប្រកាសសាលក្រមនេះមានអនុភាពអនុវត្តជាបណ្ដោះអាសន្នលើប្រាក់ដើម។

៦-ប្រាក់ប្រដាប់ក្ដី ជាបន្ទុករបស់សហចុងចម្លើយ។

**ខ**-ចុងចម្លើយឈ្មោះ ច១ បានថ្លែងការណ៍ពីលទ្ធផលនៃនីតិវិធីត្រៀមសម្រាប់ការទាញហេតុផលថា: ប្រពន្ធខ្លួនឈ្មោះ ច២ បានទទួលដំណឹងអំពីការចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់រួចហើយ តែនាពេលនេះគាត់អវត្តមាន ដោយសារគាត់ជាប់រវល់ ហើយគាត់បានអោយខ្លួនមកចូលរួមនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់នាពេលនេះ។ ខ្លួន និងប្រពន្ធឈ្មោះ ច២ ពិតជាបានខ្ចីប្រាក់ពីធនាគារចំនួន២៣,៨០០ដុល្លារអាមេរិក ដូចមានក្នុងកិច្ចសន្យាខ្ចីចងការប្រាក់ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ ប្រាកដមែន ហើយខ្លួន និងប្រពន្ធឈ្មោះ ច២ បានបង់ការប្រាក់មកធនាគារបានតែពីរខែប៉ុណ្ណោះ ស្មើនឹងទឹកប្រាក់ចំនួន៥០០ដុល្លារអាមេរិក។ ប៉ុន្តែ ចាប់តាំងខ្ចីប្រាក់ពីធនាគារមក ខ្លួន និងប្រពន្ធមិនទាន់បានសងប្រាក់ដើម និងបានអាកខានបង់ការប្រាក់មកធនាគាររហូតដល់បច្ចុប្បន្ននេះ។ ដូច្នេះ ខ្លួន និងប្រពន្ធ ទទួលស្គាល់ប្រាក់ជំពាក់ដូចការទាមទាររបស់ធនាគារពិតប្រាកដមែន។ តែនាពេលនេះ ខ្លួន និងប្រពន្ធពុំមានលទ្ធភាពសងប្រាក់មកធនាគារនៅឡើយទេ។

<u>សំណូមពរ:</u>សុំសងប្រាក់ដើមចំនួន២៣,៨០០(ពីរម៉ឺនបីពាន់ប្រាំបីរយ) ដុល្លារអាមេរិក។ រីឯ ការទាមទារការប្រាក់, ប្រាក់ពិន័យ, សំណងការខូចខាត និងជំងឺចិត្ត សំណូមពរទៅធនាគារកុំទាមទារទៀតអី ដោយសារខ្លួនពុំមានលទ្ធភាព។

**៣-<u>ចំណុចវិវាទនៃអង្គហេតុ:</u>** គ្មាន។

## <u>ការសំអាងហេតុ</u>

១-តាមសេចក្ដីថ្លែងការណ៍របស់គូភាគីមានភាពស៊ីសង្វាក់ជាមួយកិច្ចសន្យាខ្ចីចងការប្រាក់ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៧ និងភស្តុតាងជាឯកសារនានាបញ្ជាក់ថា៖ សហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ ពិតជាបានខ្ចីប្រាក់ពីដើមចោទ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ដ ប្រាកដមែន។

២-ដើមចោទឲ្យប្ដឹងសុំឲ្យសហចុងចម្លើយសងប្រាក់ដើមចំនួន២៣,៨០០ដុល្លារអាមេរិក, ការប្រាក់ចំនួន១.៣០ភាគរយក្នុងមួយខែ នៃប្រាក់ដើមចំនួន២៣,៨០០ដុល្លារអាមេរិក គិតចាប់ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ រហូតដល់សងអស់ និងប្រាក់ពិន័យចំនួន២(ពីរ)ដុល្លារអាមេរិក ក្នុងមួយថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ រហូតដល់សងអស់។ រីឯសហចុងចម្លើយក៏បានឯកភាពទទួលស្គាល់ចំពោះការទាមទាររបស់ដើមចោទផងដែរ។ គប្បី តុលាការសម្រេចតាមការប្ដឹង ៤

និងជម្ងឺចិត្តចំនួន៤,០០០,០០០រៀល ដែលការប្ដឹងទាមទារនេះគ្មានភស្តុតាងណាមួយបញ្ជាក់ពីទំហំនៃការខូចខាតនោះទេ។
*កំណត់សំគាល់៖ សាលក្រមនេះគឺជារឿងក្ដីជាក់ស្ដែង ហើយមិនមែនជាសាលក្រមគម្រូទេ*
គប្បី តុលាការពិចារណា។

៣-ដើមចោទប្ដឹងសុំឱ្យតុលាការប្រកាសឱ្យសាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នបាន។ រីឯ សហចុងចម្លើយបានទទួលស្គាល់លើការប្ដឹងទាមទាររបស់ដើមចោទនូវប្រាក់ជំពាក់ដើមចំនួន២៣,៨០០ដុល្លារអាមេរិក។ ហេតុនេះ ការថ្លែងការណ៍ទទួលស្គាល់លើប្រាក់ជំពាក់ដើមរបស់សហចុងចម្លើយ ជាហេតុឱ្យតុលាការជឿលើភាពជាក់លាក់ និងមិនបារម្ភខ្លាចអាចមានការប្រែប្រួលលើសិទ្ធិលើបំណុលដែលដើមចោទបានប្ដឹងទាមទារ។ គប្បី តុលាការសម្រេចប្រកាសសាលក្រមអនុវត្តជាបណ្ដោះអាសន្នលើប្រាក់ដើមចំនួន២៣,៨០០ដុល្លារអាមេរិក។ តាមមាត្រា១៩៦ នៃក្រមនីតិវិធីរដ្ឋប្បវេណី។

៤-ប្រាក់ប្រដាប់ក្ដី គឺជាបន្ទុករបស់អ្នកចាញ់ក្ដី។

## <u>**សេចក្តីសម្រេចបញ្ចប់**</u>

**១**-ទទួលស្គាល់ការប្ដឹងទាមទាររបស់ដើមចោទ ដោយបង្គាប់ឱ្យសហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ រួមគ្នាសងប្រាក់ទៅឱ្យ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ** ដ ដែលមានតំណាងដោយលោក តដ នូវ៖

**ក**-ប្រាក់ដើមចំនួន២៣,៨០០(ពីរម៉ឺនបីពាន់ប្រាំបីរយ)ដុល្លារអាមេរិក។

**ខ**-ការប្រាក់ចំនួន១.៣០(មួយក្បៀសសាមសិប)ភាគរយក្នុងមួយខែ នៃប្រាក់ដើមចំនួន២៣,៨០០(ពីរម៉ឺនបីពាន់ប្រាំបីរយ)ដុល្លារអាមេរិក គិតចាប់ថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ រហូតដល់សងអស់។

**គ**-ប្រាក់ពិន័យចំនួន២(ពីរ)ដុល្លារអាមេរិក ក្នុងមួយថ្ងៃ ដោយគិតចាប់ពីថ្ងៃទី០៦ ខែមេសា ឆ្នាំ២០១៨ រហូតដល់សងអស់។

**ឃ**-សំណងការខូចខាតពេលវេលា និងជម្ងឺចិត្តចំនួន ២,០០០,០០០(ពីរលាន)រៀល។

២-សាលក្រមនេះអាចអនុវត្តជាបណ្ដោះអាសន្នលើប្រាក់ដើមចំនួន២៣,៨០០(ពីរម៉ឺនបីពាន់ប្រាំបីរយដុល្លារអាមេរិក)។

៣-ប្រាក់ប្រដាប់ក្ដីជាបន្ទុករបស់សហចុងចម្លើយឈ្មោះ ច១ និងប្រពន្ធឈ្មោះ ច២ ។ល

**ចៅក្រម**

**ហត្ថលេខា និងត្រា៖ ហុង សុគុណា វឌ្ឍនា**

---

**បានឃើញ**

**ចៅក្រម**

ហុង សុគុណា វឌ្ឍនា

ថ្ងៃសុក្រ ០៨រោច ខែស្រាពណ៍ ឆ្នាំកុរ ឯកស័ក ព.ស២៥៦៣

រាជធានីភ្នំពេញ, ថ្ងៃទី២៣ ខែសីហា ឆ្នាំ២០១៩

**ក្រឡាបញ្ជី**

លី_សុលីដា



ច២ តដ ច១ ច២